*[សូមផ្ទៀងផ្ទាត់ តាមការអាន]*

# សុន្ទរកថា
# អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន ឧបនាយករដ្ឋមន្ត្រី,
# រដ្ឋមន្ត្រី ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
# ថ្លែងក្នុង
# ពិធីសម្ពោធដាក់ឱ្យដំណើរការជាផ្លូវការ នូវ «រោងចក្រប្រព្រឹត្តកម្មទឹកស្អាតបាក់ខែង ដំណាក់កាលទី ២ និង បើកការដ្ឋានសាងសង់ ដំណាក់កាលទី ៣»

រាជធានីភ្នំពេញ, ថ្ងៃអង្គារ ៤ រោច ខែជេស្ឋ ឆ្នាំរោង ឆស័ក ព.ស. ២៥៦៨

ត្រូវនឹងថ្ងៃទី ២៥ ខែ មិថុនា គ.ស. ២០២៤, វេលាម៉ោង ៩ ព្រឹក

*****+*****

- ឯកឧត្តម, លោកជំទាវ, សមាជិក-សមាជិកា នៃព្រឹទ្ធសភា, រដ្ឋសភា និង រាជរដ្ឋាភិបាល;
- ឯកឧត្តម **ហែម វណ្ណឌី**, រដ្ឋមន្ត្រី ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និង នវានុវត្តន៍;
- ឯកឧត្តម Jacques PELLET, ឯកអគ្គរដ្ឋទូតវិសាមញ្ញ និង ពេញសមត្ថភាព នៃសាធារណរដ្ឋបារាំង ប្រចាំព្រះរាជាណាចក្រកម្ពុជា;
- លោក Tihamer CZIKA, ភារធារីស្ដីទី នៃប្រតិភូសហភាពអឺរ៉ុប ប្រចាំព្រះរាជាណាចក្រកម្ពុជា;
- លោកស្រី Sandrine BOUCHER, នាយិកា នៃទីភ្នាក់ងារបារាំងសម្រាប់ការអភិវឌ្ឍ (AFD) ប្រចាំព្រះរាជាណាចក្រកម្ពុជា;
- ឯកឧត្តម, លោកជំទាវ, ឧកញ៉ា, លោក, លោកស្រី, តំណាងក្រសួង-ស្ថាប័នពាក់ព័ន្ធ, តំណាងអង្គទូត, តំណាងវិស័យឯកជន, ភ្ញៀវកិត្តិយសជាតិ និង អន្តរជាតិ;
- អ៊ុំ, ពូ-មីង, បង-ប្អូន, លោកគ្រូ-អ្នកគ្រូ, ក្មួយៗយុវជន, និង សិស្សានុសិស្ស, ជាទីមេត្រី!

ថ្ងៃនេះ, ខ្ញុំពិតជាមានកិត្តិយសដ៏ឧត្តុង្គឧត្តម និង សេចក្តីសោមនស្សក្រៃលែង ដោយបានទទួលបុព្វសិទ្ធិដ៏ខ្ពង់ខ្ពស់ ពី **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា,** មកចូលរួមជាអធិបតី ក្នុង **«ពិធីសម្ពោធដាក់ឲ្យដំណើរការជាផ្លូវការ នូវ រោងចក្រប្រព្រឹត្តកម្មទឹកស្អាតបាក់ខែង ជំហានទី ២ និង បើកការដ្ឋានសាងសង់ ជំហានទី ៣»** ។ ខ្ញុំសូមស្វាគមន៍យ៉ាងកក់ក្តៅ ចំពោះ ឯកឧត្តម, លោកជំទាវ, ឧកញ៉ា, លោក, លោកស្រី, អ៊ុំ, ពូ-មីង, បង-ប្អូន, លោកគ្រូ-អ្នកគ្រូ, ក្មួយៗយុវជន, និង សិស្សានុសិស្ស ដែលបានឆ្លៀតពេលដ៏មានតម្លៃ ចូលរួមក្នុងពិធី នាព្រឹកនេះ ។

ខ្ញុំសូមយកឱកាសដ៏ប្រពៃនេះ សម្តែងនូវការអបអរសាទរយ៉ាងកក់ក្តៅ ចំពោះថ្នាក់-ដឹកនាំ និង មន្ត្រី-បុគ្គលិកគ្រប់ជាន់ថ្នាក់ នៃរដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ ដែលបានខិតខំបំពេញតួនាទី និង ភារកិច្ចរបស់ខ្លួន ដោយស្មារតីទទួលខុសត្រូវខ្ពស់ រហូតសម្រេចបាននូវសមិទ្ធផលជាប្រវត្តិសាស្ត្រថ្មីមួយទៀត ក្នុងការជំរុញ និង ការបង្កើនគុណភាព និង ប្រសិទ្ធភាពនៃការផ្តល់សេវាផ្គត់ផ្គង់ទឹកស្អាត ឲ្យបានកាន់តែប្រសើរ សម្រាប់បង-ប្អូនប្រជា-ពលរដ្ឋ ក្នុងភូមិសាស្ត្ររាជធានីភ្នំពេញ និង ក្រុងតាខ្មៅនៃខេត្តកណ្តាល ។ ដូច ឯកឧត្តម **ហែម វណ្ណឌី**, រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និង នវានុវត្តន៍, បានរាយការណ៍ នៅមុននេះបន្តិច, រោងចក្រប្រព្រឹត្តកម្មទឹកស្អាតបាក់ខែង ជំហានទី ២, ដែលត្រូវបានសម្ពោធដាក់ឲ្យដំណើរការជាផ្លូវការ នាពេលនេះ, មានសមត្ថភាពផលិតទឹកស្អាតបានចំនួនប្រមាណ ១៩ ម៉ឺន ៥ ពាន់ម៉ែត្រគូប បន្ថែមទៀត ក្នុងមួយថ្ងៃ ។ សរុបជារួម, បច្ចុប្បន្ន, រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ អាចផលិតទឹកស្អាតបាន ចំនួនប្រមាណ ៩៨ ម៉ឺន ២ ពាន់ម៉ែត្រគូប ក្នុងមួយថ្ងៃ, ដែលបរិមាណនេះ អាចឆ្លើយតបទៅនឹងតម្រូវការបច្ចុប្បន្ន របស់បង-ប្អូនប្រជាពលរដ្ឋ នៅក្នុងរាជធានីភ្នំពេញ និង ក្រុងតាខ្មៅនៃខេត្តកណ្តាល ។ ក្នុងឱកាសដ៏ថ្លៃថ្លានេះ, ជាមួយនឹងសេចក្តីរីករាយក្រៃលែង, ខ្ញុំសូមប្រកាសថា ការដាក់ឲ្យដំណើរការ នូវរោងចក្រប្រព្រឹត្តកម្មទឹកស្អាត ជំហានទី ២ នាពេលនេះ គឺជាការបិទបញ្ចប់ទាំងស្រុង នូវបញ្ហាកង្វះទឹកស្អាត នៃផ្ទៃសេវាគ្របដណ្តប់ របស់រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ ដែលធ្លាប់បានកើតមានដោយអន្លើ នាពេលកន្លងទៅ នៅក្នុងភូមិសាស្ត្រខ្លះ នៃរាជធានីភ្នំពេញ និង ក្រុងតាខ្មៅ នៃខេត្តកណ្តាល ។

ខ្ញុំក៏សូមយកឱកាសដ៏វិសេសនេះ សម្តែងនូវការកោតសរសើរ និង ការវាយតម្លៃខ្ពស់ ចំពោះក្រុមប្រឹក្សាភិបាល, ថ្នាក់ដឹកនាំ, និង មន្ត្រី-និយោជិតទាំងអស់ នៃរដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ ដែលបានយកអស់នូវកម្លាំងកាយ-ចិត្ត និង ប្រាជ្ញា-ស្មារតី ក្នុងការបំពេញ

តួនាទី និង ភារកិច្ចរបស់ខ្លួនយ៉ាងសកម្ម ដើម្បីជានានូវការផ្គត់ផ្គង់ទឹកស្អាត ជូនប្រជាពលរដ្ឋ ប្រើប្រាស់គ្រប់គ្រាន់ និង គ្រប់ពេល, ជាមួយនឹងការផ្តល់នូវសេវាល្អ និង រហ័ស ។ ទន្ទឹមនេះ, ខ្ញុំក៏សូមកោតសរសើរ និង ថ្លែងអំណរគុណផងដែរ ដល់ដៃគូអភិវឌ្ឍន៍ទាំងអស់, ពិសេស ទីភ្នាក់ងារបារាំងសម្រាប់ការអភិវឌ្ឍ (AFD) និង សហភាពអឺរ៉ុប (EU) ដែលបានសហការ ផ្តល់ហិរញ្ញប្បទាន ដល់រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ, ម្យ៉ាង, ដើម្បីអនុវត្តគម្រោងសាងសង់ រោងចក្រប្រព្រឹត្តកម្មទឹកស្អាតបាក់ខែង ដំហានទី ២ រហូតសម្រេចបានជាផ្លែផ្កាដ៏ត្រចះត្រចង់; និង ម្យ៉ាងទៀត, ដើម្បីផ្តល់លទ្ធភាពបន្ត ឲ្យយើងអាចបើកការដ្ឋាន សម្រាប់គម្រោងសាង-សង់រោងចក្រប្រព្រឹត្តកម្មទឹកស្អាតបាក់ខែង ដំហានទី ៣ ដែលគ្រោងនឹងបញ្ចប់ នៅ ត្រឹមាសទី ៣ ឆ្នាំ ២០២៧ ខាងមុខ ។ បន្ទាប់ពីគម្រោងសាងសង់ ដំហានទី ៣ ត្រូវបាន បញ្ចប់, រោងចក្រប្រព្រឹត្តកម្មទឹកស្អាតបាក់ខែង នឹងមានសមត្ថភាពផលិតទឹកស្អាត បានចំនួន ប្រមាណ ១៩ ម៉ឺន ៥ ពាន់ម៉ែត្រគូប បន្ថែមទៀត ក្នុងមួយថ្ងៃ ដើម្បីឆ្លើយតបទៅនឹងតម្រូវការ ទឹកស្អាតប្រចាំថ្ងៃ ពីសំណាក់បង-ប្អូនប្រជាពលរដ្ឋ នៅក្នុងរាជធានីភ្នំពេញ និង ក្រុងតាខ្មៅ នៃខេត្តកណ្តាល ដែលចេះតែបន្តកើនឡើងជាលំដាប់ ។

ខ្ញុំក៏សូមគូសបញ្ជាក់ផងដែរថា គម្រោងសាងសង់រោងចក្រប្រព្រឹត្តកម្មទឹកស្អាត បាក់ខែងទាំង ៣ ដំហាន គ្រោងនឹងចំណាយថវិកា សរុបចំនួនប្រមាណ ៦៦០ លាន ដុល្លារអាមេរិក, ដែលក្នុងនោះ រួមមាន៖ ឥណទានសម្បទានពី AFD ចំនួន ៤១០ លាន ដុល្លារអាមេរិក, ឥណទានសម្បទានពីធនាគារវិនិយោគអឺរ៉ុប (EIB) ចំនួន ១០០ លានដុល្លារ អាមេរិក, ហិរញ្ញប្បទានឥតសំណងពីសហគមន៍អឺរ៉ុប (EU) ចំនួន ២៦ លានដុល្លារអាមេរិក, និង ថវិកាបដិភាគពីរដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ ចំនួន ១២៤ លានដុល្លារអាមេរិក ។

## *ឯកឧត្តម, លោកជំទាវ, ឧកញ៉ា, លោក, លោកស្រី!*

ក្នុងរយៈពេល ២៦ ឆ្នាំចុងក្រោយ, បន្ទាប់ពីការសម្រេចបាននូវសុខសន្តិភាព ពេញលេញ, ឯកភាពជាតិ និង ឯកភាពទឹកដីទាំងស្រុង តាមរយៈ **នយោបាយឈ្នះ-ឈ្នះ** របស់ **សម្តេចតេជោ ហ៊ុន សែន**, **អតីតនាយករដ្ឋមន្ត្រី** និង បច្ចុប្បន្នជា **ប្រធាន ព្រឹទ្ធសភា**, រាជរដ្ឋាភិបាលកម្ពុជា សម្រេចបាននូវសមិទ្ធផលធំធេង លើគ្រប់វិស័យ, ទាំង នយោបាយ, សង្គម, និង សេដ្ឋកិច្ច, ដែលនាំឱ្យកម្ពុជា មានការផ្លាស់ប្តូរមុខមាត់ថ្មី គួរជាទី មោទនៈបំផុត ។

ពេលនេះ, ដំណើរការកសាងជាតិរបស់កម្ពុជា បានឈានដល់ដំណាក់កាលថ្មីមួយ នៅក្នុងបរិការណ៍នៃពិភពលោក ដែលកាន់តែប្រែប្រួល, លំបាក និង មិនប្រាកដប្រជា ។ ច្បាស់ណាស់ថា នៅក្នុងបរិបទថ្មីនេះ, កម្ពុជាត្រូវសម្របជាប្រចាំ តាមនិន្នាការប្រែប្រួលសកល ដែលទាមទារនូវការយកចិត្តទុកដាក់ខ្ពស់ ចំពោះការលើកកម្ពស់ភាពជាអ្នកដឹកនាំ និង សមត្ថភាពស្ថាប័នគ្រប់កម្រិត ដោយផ្សារភ្ជាប់នឹងការធានាបាន នូវគោលនយោបាយសមស្រប និង សមត្ថភាពអនុវត្តជាក់ស្តែង, លទ្ធផលការងារ និង ការទទួលខុសត្រូវខ្ពស់, ដើម្បីឆ្លើយតបនឹងអាទិភាពសំខាន់ៗ នៅក្នុងដំណាក់កាលថ្មី រួមមាន៖ ការពង្រឹងអភិបាល-កិច្ច; ការទ្រទ្រង់កំណើន និង ការធ្វើទំនើបកម្មសេដ្ឋកិច្ច; ការបង្កើតការងារ, ទាំងគុណ-ភាព និង បរិមាណ; ការលើកស្ទួយវិស័យឯកជន និង សហគ្រិនភាព; ការកសាងមូលធនមនុស្ស ដោយផ្តោតជាពិសេស លើគុណភាពវិស័យអប់រំ, សេវាសុខាភិបាល និង សីលធម៌សង្គម; ការលើកស្ទួយសេវាគាំពារសង្គម និង សុខុមាលភាពប្រជាជន, ជាពិសេស សម្រាប់គ្រួសារងាយរងហានិភ័យ និង ក្រុមជនងាយរងគ្រោះ; ការពង្រឹងគុណភាពនគរូបនីយកម្ម, ជាពិសេស ការកាត់បន្ថយគម្លាតរវាងទីក្រុង និង ជនបទ; ការពង្រឹងចីរភាពបរិស្ថាន និង ការឆ្លើយតបទៅនឹងការប្រែប្រួលអាកាសធាតុ; ព្រមទាំង ការជំរុញធ្វើបរិវត្តកម្មឌីជីថល, ទាំងក្នុងសង្គម និង សេដ្ឋកិច្ច ។

នៅក្នុងក្របខណ្ឌនៃទស្សនវិស័យនេះ និង ផ្អែកតាម **កម្មវិធីនយោបាយ** របស់ខ្លួន, រាជរដ្ឋាភិបាល នីតិកាលទី ៧ នៃរដ្ឋសភា, ក្រោមការដឹកនាំដ៏ត្រឹមត្រូវ, ស្វាហាប់, និង ឈ្លាសវៃ ប្រកបដោយចក្ខុវិស័យវែងឆ្ងាយ របស់ **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត** ដែលជាអគ្គមគ្គុទ្ទេសក៍វ័យក្មេងដ៏ឆ្នើម និង ពោរពេញដោយសមត្ថភាព, ចំណេះដឹង, និង ថាមពល, បានដាក់ចេញ នូវ **យុទ្ធសាស្ត្របញ្ចកោណ-ដំណាក់-កាលទី ១** ដើម្បី **កំណើន, ការងារ, សមធម៌, ប្រសិទ្ធភាព, និង ចីរភាព**, ដោយផ្តោតជាសំខាន់ លើរបៀបវារៈធានា «**ប្រសិទ្ធភាពសមិទ្ធកម្ម**» តាមរយៈការអនុវត្តអភិក្រម «**ឆ្លុះកញ្ចក់, ងូតទឹក, ដុសក្អែល, ព្យាបាល, និង វះកាត់**» និង អភិក្រម «**ជីវភាពនៃប្រព័ន្ធតួអង្គតែមួយ**» ។ **យុទ្ធសាស្ត្របញ្ចកោណ-ដំណាក់កាលទី ១** បានកំណត់យក **អាទិភាពគន្លឹះ ៥** គឺ៖ «**មនុស្ស, ផ្លូវ, ទឹក, ភ្លើង**, និង **បច្ចេកវិទ្យា**, ជាពិសេស គឺ **បច្ចេកវិទ្យាឌីជីថល**» សម្រាប់ឆ្លើយតបទៅនឹងបដិវត្ត ឧស្សាហកម្មទី ៤.០ និង បរិវត្តកម្មឌីជីថលនៃសេដ្ឋកិច្ច និង សង្គមកម្ពុជា ក៏ដូចជា ឆ្លើយតបនឹងតម្រូវការ ក្នុងការលើកកម្ពស់ផលិត-

ភាពសេដ្ឋកិច្ច ដែលជាគ្រឹះ និង ជាមធ្យោបាយដ៏សំខាន់ ក្នុងការសម្រេចបាននូវ **ចក្ខុវិស័យកម្ពុជា ឆ្នាំ ២០៥០** សំដៅប្រែក្លាយកម្ពុជា ទៅជាប្រទេសមានចំណូលខ្ពស់ ។

ជាផ្នែកមួយនៃ **អាទិភាពគន្លឹះ ២**, ពោលគឺ **«មនុស្ស និង ទឹក»**, ក្នុងចំណោម **អាទិភាពគន្លឹះ ទាំង ៥** ខាងលើ, រាជរដ្ឋាភិបាល បាន និង កំពុង បន្តតួនាទីជាយុទ្ធសាស្ត្ររបស់ខ្លួន ក្នុងការពង្រឹងការគ្រប់គ្រង និង ការអភិវឌ្ឍវិស័យទឹកស្អាត, ដោយមានការចូលរួមពីសំណាក់វិស័យឯកជនផងដែរ, ដើម្បីឆ្លើយតបទៅនឹងតម្រូវការទឹកស្អាតប្រចាំថ្ងៃ របស់បង-ប្អូនប្រជាពលរដ្ឋទូទៅ និង តម្រូវការទឹកស្អាត នៅតាមទីតាំងពាណិជ្ជកម្មជាអាទិភាពនានា មានជាអាទិ៍ៈ រោងចក្រ, សហគ្រាស, តំបន់សេដ្ឋកិច្ចពិសេស, សួនបណ្តុំសហគ្រាសធុនតូច និង មធ្យម, និង តំបន់ប៉ូលសេដ្ឋកិច្ច នៅរាជធានីភ្នំពេញ និង តាមបណ្តាខេត្តផ្សេងទៀត, ដែលទីតាំងទាំងនេះ គឺជាកន្លែងដែលផ្តល់នូវឱកាសការងារ និង ជាកម្លាំងចលករដ៏សំខាន់ ក្នុងការរួមចំណែកជំរុញកំណើនសេដ្ឋកិច្ចជាតិ និង លើកកម្ពស់កម្រិតជីវភាពរបស់ប្រជាពលរដ្ឋ ។

### *ឯកឧត្តម, លោកជំទាវ, ឧកញ៉ា, លោក, លោកស្រី!*

ការសម្រេចបាននូវសមិទ្ធផលដ៏ធំនៃវិស័យទឹកស្អាត, តាមរយៈការសាងសង់រោងចក្រប្រព្រឹត្តកម្មទឹកស្អាតបាក់ខែង ជំហានទី ១, ជំហានទី ២, និង ជំហានទី ៣, ដែលផ្តល់លទ្ធភាពនៃការផលិតទឹកស្អាត រហូតដល់ចំនួនជាង ១ លាន ១៧ ម៉ឺនម៉ែត្រគូប ក្នុងមួយថ្ងៃ តាមផែនការរំពឹងទុក នៅត្រឹមចុងឆ្នាំ ២០២៧ ខាងមុខ, ឆ្លុះបញ្ចាំងយ៉ាងច្បាស់ អំពីជោគជ័យនៃការអនុវត្តអភិក្រម **«ជីវភាពនៃប្រព័ន្ធតួអង្គតែមួយ»**, ពោលគឺ ក្រសួង-ស្ថាប័ននៃរាជរដ្ឋាភិបាល, ជាពិសេស ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ និង ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្របច្ចេកវិទ្យា និង នវានុវត្តន៍, បានប្រកាន់យកនូវ អភិក្រមនៃការអនុវត្តការងារ និង កិច្ចសហការសម្របសម្រួលស្អិតល្មួត ប្រកបដោយស្មារតីបុរេសកម្ម, អន្តរសកម្ម, ម៉ឺងម៉ាត់, និង ច្បាស់លាស់ ។

ដើម្បីគាំទ្រដល់ការអនុវត្តកម្មវិធីនយោបាយ និង គោលនយោបាយ របស់រាជរដ្ឋាភិបាល, រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ កំពុងបន្តពង្រឹងសមត្ថភាពរបស់ខ្លួន ក្នុងការផលិត និង ការផ្គត់ផ្គង់ទឹកស្អាត ជូនដល់ប្រជាពលរដ្ឋនៅក្នុងរាជធានីភ្នំពេញ និង ក្រុងតាខ្មៅនៃខេត្តកណ្តាល ស្របតាមផែនការមេរបស់ខ្លួន ។ បន្ថែមលើនេះ, ដោយមានការយកចិត្តទុកដាក់ និង ការគាំទ្រពីសំណាក់រាជរដ្ឋាភិបាល, តាមរយៈក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ, រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ សម្រេចបាននូវសមិទ្ធផលជាច្រើន ជាបន្តបន្ទាប់,

ដូច ឯកឧត្តម **ហែម វណ្ណឌី**, រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និង នវានុវត្តន៍, បានគូសបញ្ជាក់នៅមុននេះបន្តិច, ជាពិសេស ការសម្ពោធដាក់ឲ្យដំណើរការជាផ្លូវការ នូវរោងចក្រប្រព្រឹត្តកម្មទឹកស្អាតបាក់ខែង ដំហានទី ២ និង ការបើកការដ្ឋានសាងសង់ ដំហានទី ៣ នាពេលនេះ ។

សម្រាប់ទិសដៅអនាគត, រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ ចាំបាច់ត្រូវបន្តបេសកកម្ម និង តួនាទីរបស់ខ្លួន ដើម្បីបង្កើនសមត្ថភាពផលិត ឲ្យកាន់តែសកម្មខ្លាំងក្លាបន្ថែមទៀត ដើម្បីសម្រេចបាននូវគុណភាព, ប្រសិទ្ធភាព, និង ជវភាពខ្ពស់, សំដៅឈានឆ្ពោះទៅសម្រេចបាន នូវគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព ក្នុងការផ្គត់ផ្គង់ទឹកស្អាត ជូនដល់បង-ប្អូនប្រជាពលរដ្ឋ ។ ក្នុងស្មារតីនេះ, ខ្ញុំសូមស្នើឱ្យក្រុមប្រឹក្សាភិបាល, ថ្នាក់ដឹកនាំ និង មន្ត្រី-និយោជិតគ្រប់លំដាប់ថ្នាក់នៃរដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ, ថ្នាក់ដឹកនាំនៃក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និង នវានុវត្តន៍, ក៏ដូចជា ក្រសួង-ស្ថាប័នពាក់ព័ន្ធ, ទាំងនៅថ្នាក់ជាតិ និង ថ្នាក់ក្រោមជាតិ, បន្តយកចិត្តទុកដាក់លើការងារអាទិភាពមួយចំនួនដូចខាងក្រោម ៖

**ទី១**-ក្រសួង-ស្ថាប័ន, រដ្ឋបាលថ្នាក់ក្រោមជាតិ និង ភាគីពាក់ព័ន្ធទាំងអស់ ត្រូវបន្តសហការជិតស្និទ្ធ ជាមួយក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និង នវានុវត្តន៍ ដើម្បីអនុវត្តច្បាប់ស្តីពីការគ្រប់គ្រងទឹកស្អាត សំដៅធានាឲ្យបាននូវប្រភពទឹកគ្រប់គ្រាន់, ដោយមិនបង្កផលប៉ះពាល់អវិជ្ជមានដល់បរិស្ថាន, ដើម្បីឲ្យការផ្គត់ផ្គង់ទឹកស្អាត សម្រេចបាននូវលក្ខខណ្ឌគោលទាំង ៤ គឺ៖ **គុណភាព, សុវត្ថិភាព, និរន្តរភាព, និង ថ្លៃសមរម្យ** ។

**ទី២**-ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និង នវានុវត្តន៍ ព្រមទាំងរដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ ត្រូវបន្តពង្រីកវិសាលភាពនៃការផ្គត់ផ្គង់ទឹកស្អាត តាមប្រព័ន្ធបណ្តាញមេ ជូនដល់ប្រជាពលរដ្ឋ, ទាំងនៅទីប្រជុំជន និង ក្រៅទីប្រជុំជន, តាមរយៈការលើកទឹកចិត្ត ឲ្យវិស័យឯកជនចូលរួមវិនិយោគបន្ថែម ក្នុងការផលិតទឹកស្អាត, ទាំងខ្នាតធំ និង មធ្យម, ដើម្បីជួយផ្គត់ផ្គង់ទឹកស្អាត ដល់តំបន់ដែលប្រឈមនឹងកង្វះទឹក ។ ទន្ទឹមនេះ, ក្រសួងក៏ត្រូវបន្តពង្រឹងការអនុវត្តច្បាប់ និង លិខិតបទដ្ឋានគតិយុត្តជាធរមាន ក្នុងការគ្រប់គ្រងអាជ្ញាបណ្ណ ឲ្យបានមត់ចត់ ព្រមទាំងបន្តជួយពង្រឹងសមត្ថភាពរបស់ប្រតិបត្តិករឯកជនក្នុងការផ្តល់សេវាផ្គត់ផ្គង់ទឹកស្អាត ឲ្យបានកាន់តែប្រសើរ ផងដែរ ។ និង

**ទី៣**-ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និង នវានុវត្តន៍, ក៏ដូចជា រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ, ត្រូវបន្តអនុវត្តគោលនយោបាយថ្លៃទឹកស្អាត ដោយត្រូវផ្តល់

អាទិភាព ដល់ប្រជាពលរដ្ឋដែលមានចំណូលទាប រួមទាំងកម្មករ-និយោជិត និង សិស្ស-និស្សិត ដែលស្នាក់នៅតាមបន្ទប់ជួល ឲ្យទទួលបានទឹកស្អាតប្រើប្រាស់ ក្នុងថ្លៃសមរម្យ ដែលអាចទទួលយកបាន; និង ត្រូវបន្តពង្រឹង និង ពង្រីកតួនាទីជាយុទ្ធសាស្ត្ររបស់រដ្ឋ ដើម្បីធានាប្រសិទ្ធភាព និង ស័ក្តិសិទ្ធភាពនៃការផ្គត់ផ្គង់ទឹកស្អាត ឲ្យបានគ្រប់គ្រាន់ និង ទាន់ពេល សម្រាប់រោងចក្រ, សហគ្រាស, តំបន់ឧស្សាហកម្ម, តំបន់សេដ្ឋកិច្ចពិសេស, តំបន់កសិ-ឧស្សាហកម្ម, សួនបណ្តុំសហគ្រាសធុនតូច និង មធ្យម, និង ទីប្រជុំជន ដែលមានសកម្មភាពសេដ្ឋកិច្ច និង នគរូបនីយកម្ម រីកដុះដាលលឿន ។

## *ឯកឧត្តម, លោកជំទាវ, ឧកញ៉ា, លោក, លោកស្រី!*

មុននឹងបញ្ចប់, ជាថ្មីម្តងទៀត, ខ្ញុំសូមអបអរសាទរ, កោតសរសើរ, និង វាយតម្លៃខ្ពស់ ចំពោះកិច្ចខិតខំទាំងឡាយ និង ស្នាដៃក្នុងការបំពេញការងារ ឈរលើស្មារតីទទួល-ខុសត្រូវខ្ពស់ របស់ក្រុមប្រឹក្សាភិបាល, ថ្នាក់ដឹកនាំ និង មន្ត្រី-និយោជិត នៃរដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ ក៏ដូចជា ថ្នាក់ដឹកនាំ និង មន្ត្រីរាជការគ្រប់លំដាប់ថ្នាក់ នៃក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និង នវានុវត្តន៍ ។ ជាមួយគ្នានេះ, ក្នុងនាមប្រជាជនកម្ពុជា, ជាពិសេស បង-ប្អូនដែលរស់នៅរាជធានីភ្នំពេញ និង ក្រុងតាខ្មៅនៃខេត្តកណ្តាល, ខ្ញុំសូមថ្លែងអំណរគុណដ៏ជ្រាលជ្រៅ ចំពោះដៃគូអភិវឌ្ឍន៍ទាំងអស់ ដែលតែងផ្តល់នូវកិច្ច-សហប្រតិបត្តិការល្អ, ក្នុងភាពជាដៃគូមិនអាចខ្វះបាន, ជាមួយរាជរដ្ឋាភិបាលកម្ពុជា ក្នុងការ-អភិវឌ្ឍវិស័យទឹកស្អាត នៅព្រះរាជាណាចក្រកម្ពុជា ។ ខ្ញុំសង្ឃឹមថា រដ្ឋាភិបាលបារាំង, រដ្ឋាភិ-បាលជប៉ុន, ធនាគារវិនិយោគអឺរ៉ុប, សហភាពអឺរ៉ុប, មូលនិធិសហប្រតិបត្តិការអភិវឌ្ឍន៍សេដ្ឋ-កិច្ចនៃសាធារណរដ្ឋកូរ៉េ ព្រមទាំងប្រទេសជាដៃគូអភិវឌ្ឍន៍ផ្សេងទៀត នឹងបន្តជួយគាំទ្រ, ទាំងហិរញ្ញវត្ថុ និង បច្ចេកទេស, ដល់រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ ដើម្បីធានាថា រាល់ការអនុវត្តគម្រោងទាំងឡាយ អាចសម្រេចបានដោយជោគជ័យ ស្របតាមផែនការមេ លើកទី ៣, ពីឆ្នាំ ២០២១ ដល់ឆ្នាំ ២០៣០, និង ក្នុងរយៈពេលវែងទៅមុខ សំដៅសម្រេចបាននូវគោលដៅផ្គត់ផ្គង់ទឹកស្អាត ១០០% ជូនប្រជាពលរដ្ឋ នៅទូទាំងប្រទេស ។

ជាទីបញ្ចប់, ខ្ញុំសូមជូនពរ ឯកឧត្តម, លោកជំទាវ, ឧកញ៉ា, លោក, លោកស្រី, អ៊ុំ, ពូ-មីង, បង-ប្អូន, លោកគ្រូ-អ្នកគ្រូ, ក្មួយៗយុវជន និង សិស្សានុសិស្ស, សមាជិក-សមាជិកា នៃអង្គពិធីទាំងមូល បានប្រកបដោយសុខភាពល្អបរិបូរណ៍, កម្លាំងមាំមួន, មានសុភមង្គលក្នុងក្រុមគ្រួសាររៀងៗខ្លួន និង សម្រេចបានជោគជ័យដ៏ត្រចះត្រចង់ ក្នុងគ្រប់ភារកិច្ច

*[សូមផ្ទៀងផ្ទាត់ តាមការអាន]*

នៅក្រោមម្លប់ដ៏ត្រជាក់នៃសុខសន្តិភាពដែល **សម្តេចតេជោ ហ៊ុន សែន** បាននាំមកជូនជាតិ និង ប្រជាជនកម្ពុជា ។

ក្នុងនាម **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា, ខ្ញុំសូមប្រកាសដាក់ឱ្យប្រើប្រាស់ជាផ្លូវការ នូវ **រោងចក្រប្រព្រឹត្តកម្មទឹកស្អាតបាក់ខែង ជំហានទី ២ និង សូមប្រកាសបើកការដ្ឋានសាងសង់ ជំហានទី ៣** ចាប់ពីពេលនេះតទៅ ៕

*សូមអរគុណ !*